United Nations
Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

# អនុគណៈកម្មាធិការអ.ស.បទទួលបន្ទុកបង្ការទារុណកម្ម បញ្ចប់សម័យប្រជុំលើកទីប្រាំពីរ ប្រកាសកម្មវិធីការងារនៅតាមតំបន់សំរាប់ឆ្នាំ២០០៩

ទីក្រុងហ្ស៊ឺណែវ-- អនុគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកបង្ការទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (SPT) បានប្រកាសកម្មវិធីការងាររបស់ខ្លួននៅតាមតំបន់សំរាប់ឆ្នាំ២០០៩។

នៅក្នុងសម័យប្រជុំលើកទីប្រាំពីររបស់ខ្លួនដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៩ដល់ថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ២០០៩ អនុគណៈកម្មាធិការ(SPT) បានជូនដំណឹងទៅអាជ្ញាធរនៃប្រទេសហុងឌូរ៉ាស់និងអាជ្ញាធរនៃប្រទេសកម្ពុជាអំពីគំរោងរបស់ខ្លួន ក្នុងការធ្វើទស្សនកិច្ចទៅកាន់រដ្ឋភាគីទាំងពីរនេះ។ [...] ប្រទេសដែលត្រូវទទួលការធ្វើទស្សនកិច្ចនៅក្នុងឆ្នាំ២០០៩ ត្រូវបានជ្រើសរើសស្របតាមពិធីសារបន្ថែម។ [...]

អនុគណៈកម្មាធិការ(SPT) មានសមាសភាពសមាជិកដែលជាអ្នកជំនាញការឯករាជ្យ ចំនួនដប់រូប ដែលត្រូវបំពេញទស្សនកិច្ចបង្ការទៅកាន់កន្លែងឃុំឃាំងនានាក្នុងរដ្ឋភាគីទាំងអស់នៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។

អនុគណៈកម្មាធិការ(SPT)មានអាណត្តិមួយ ដើម្បីទស្សកិច្ចទៅកាន់រដ្ឋភាគីទាំងអស់ ក្នុងគោលបំណងដើម្បីពង្រឹង ប្រសិនជាចាំបាច់ នូវការការពារបុគ្គលទាំងឡាយដែលត្រូវគេដកហូតសេរីភាព ប្រឆាំងនឹងការធ្វើទារុណកម្ម និងទម្រង់ឯទៀតនៃការប្រព្រឹត្តឃោឃៅ អមនុស្សធម៌ ។ រដ្ឋភាគីទាំងអស់មានកាតព្វកិច្ច ស្របតាមពិធីសារបន្ថែម អនុញ្ញាតឲ្យអនុគណៈកម្មាធិការ(SPT)ចូលដោយគ្មានការរិតត្បិត ក្នុងកន្លែងឃុំឃាំងទាំងអស់ និងផ្តល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ តាមការស្នើសុំ ដល់អនុគណៈកម្មាធិការ(SPT)។ អនុគណៈ

កម្មាធិការ(SPT)អាចធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយបុគ្គលទាំងឡាយដែលត្រូវគេដកហូត សេរីភាព និងជាមួយអ្នកឯទៀត ដែលអនុគណៈកម្មាធិការ(SPT) ជឿថាអាចផ្តល់ព័ត៌មាន ពាក់ព័ន្ធ។

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងអនុគណៈកម្មាធិការ(SPT) និងរដ្ឋភាគីនានា អនុគណៈកម្មាធិការ(SPT) និងឆ្លៀតឱកាសនេះដើម្បីបន្តការពិភាក្សាអំពីយន្តការបង្ការថ្នាក់ជាតិ (NPMs) ដែលរដ្ឋភាគីនានា មានភារៈត្រូវបង្កើត និងរក្សាឲ្យមាន។ ការផ្តល់ជាយោបល់និងការជួយក្នុងការបង្កើតយន្តការបង្ការថ្នាក់ជាតិដែលឯករាជ្យនិងមានប្រសិទ្ធភាព គឺជាកត្តាមួយដ៏សំខាន់ក្នុងការងាររបស់អនុគណៈកម្មាធិការ(SPT) ហើយវានឹងបង្កើតជាផ្នែកមួយដ៏សំខាន់នៃការងារក្នុងប្រទេសនីមួយៗ។

កម្ពុជាបានក្លាយជាភាគីមួយពេញសិទ្ធិនៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម (OPCAT) ក្នុងឆ្នាំ២០០៧ ហើយគួរតែបានបង្កើតយន្តការបង្ការថ្នាក់ជាតិ(NPM) របស់ខ្លួននៅត្រឹមខែមេសា ឆ្នាំ២០០៨។

*សំរាប់ព័ត៌មានបន្ថែម សូមមេត្តាទាក់ទង ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា(OHCHR Cambodia Office) តាមរយៈទូរស័ព្ទលេខ០១២ ៩៨៧ ៦៧១ ឬអ៊ីម៉េលមក cambodia@ohchr.org ឬ មើល cambodia@ohchr.org ។*

*សំរាប់ព័ត៌មានបន្ថែមអំពីការងាររបស់អនុគណៈកម្មាធិការ(SPT)  សូមមើលវិបសាយរបស់អនុគណៈកម្មាធិការ(SPT) www.ohchr.org/english/bodies/cat/opcat*